ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខៈ ៩០២ សហវ.ប្រក.

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៩

# ប្រកាស
## ស្តីពី
## ការបង្កើត និងដាក់ឲ្យដំណើរការយន្តការភាពជាដៃគូគយ-ផ្នែកឯកជន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៤ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងឋានៈនាយកដ្ឋានគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឲ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញសេចក្តីជូនដំណឹងលេខ ៥០៦ សជណ ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០០៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១.-**

បង្កើត និងដាក់ឲ្យដំណើរការយន្តការភាពជាដៃគូគយ-ផ្នែកឯកជន (Customs-Private Sector Partnership Mechanism) ដែលមានសមាសភាពដឹកនាំដូចតទៅ ៖

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម **ម៉ែន ស៊ីម៉ន** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា អគ្គនាយកគយនិងរដ្ឋាករកម្ពុជា | ប្រធាន |
| ២- | លោក **គុណ ញឹម** | អគ្គនាយករងគយនិងរដ្ឋាករកម្ពុជា | អនុប្រធាន |
| ៣- | ប្រធាននាយកដ្ឋានកិច្ចការច្បាប់ សវនកម្ម និងទំនាក់ទំនងសាធារណៈ | នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | អនុប្រធានអចិន្ត្រៃយ៍ |
| ៤- | ប្រធាននាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ | នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | អនុប្រធាន |
| ៥- | ប្រធាននាយកដ្ឋានរបបគយ | | អនុប្រធាន |
| ៦- | តំណាងសភាពាណិជ្ជកម្មកម្ពុជា | | អនុប្រធាន |
| ៧- | តំណាងសមាគមរោងចក្រកាត់ដេរកម្ពុជា | | អនុប្រធាន |
| ៨- | តំណាងសមាគមសហគ្រាសតូច-មធ្យមកម្ពុជា | | សមាជិក |
| ៩- | តំណាងសមាគមដឹកជញ្ជូនកម្ពុជា | | សមាជិក |
| ១០- | លោក **ប៊ុរ ប៊ុនណារ៉ា** | ប្រធានការិយាល័យគយ និងរដ្ឋាករ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | សមាជិក |
| ១១- | លោក **សុខ សុទិន្ទា** | ជំនួយការលេខាធិការដ្ឋាននៃអគ្គនាយកដ្ឋាន គយ និងរដ្ឋាករកម្ពុជា | លេខាធិការ |
| ១២- | លោក **ផា អេខម៉េខ** | អនុប្រធានការិយាល័យត្រួតពិនិត្យ នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | លេខាធិការ |

យន្តការនេះមានលេខាធិការដ្ឋាន នៅទីចាត់ការកណ្តាលនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងមានសិទ្ធិប្រើប្រាស់ត្រារបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ក្នុងការងាររបស់ខ្លួន ។ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ត្រូវចាត់ចែងធានាទូវនិរន្តរភាពនៃកិច្ចដំណើរការរបស់លេខាធិការដ្ឋាននៃយន្តការនេះ ។

**ប្រការ ២.-**

យន្តការភាពជាដៃគូគយ-ផ្នែកឯកជន ត្រូវបានបែងចែកជាបីក្រុមការងារជំនាញដូចតទៅ ៖

១- ក្រុមការងារគយ-ឧស្សាហកម្មបម្រើការនាំចេញវិស័យកាត់ដេរ (Customs-Export Oriented Garment Industry Working Group)

២- ក្រុមការងារគយ-ឧស្សាហកម្មបម្រើការនាំចេញវិស័យមិនមែនកាត់ដេរ (Customs-Export Oriented Non-Garment Industry Working Group)

៣- ក្រុមការងារគយ-ធុរកិច្ចបម្រើទីផ្សារក្នុងស្រុក (Customs-Domestic Market Oriented Business Working Group)

**ប្រការ ៣.-**

ក្រុមការងារគយ-ឧស្សាហកម្មបម្រើការនាំចេញវិស័យកាត់ដេរ មានសមាសភាពដូចខាងក្រោម ៖

ក- តំណាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ៖

- ប្រធាននាយកដ្ឋានកិច្ចការច្បាប់ សវនកម្ម និងទំនាក់ទំនងសាធារណៈ សហប្រធាន
- ប្រធាននាយកដ្ឋានរបបគយ អនុប្រធានអចិន្ត្រៃយ៍
- ប្រធានការិយាល័យគយនិងរដ្ឋាករនាំចេញ សមាជិក
- លោក **ផា អេងម៉េង** អនុប្រធានការិយាល័យត្រួតពិនិត្យ សមាជិក
- លោក **ប្រាក់ សុម៉េត** អនុប្រធានការិយាល័យគោលនយោបាយនិងគ្រប់គ្រងតំបន់រួចពន្ធ សមាជិក
- លោក **សុខ សុមិត្តា** ជំនួយការលេខាធិការដ្ឋាន សមាជិក
- លោក **ម៉ុន ជីម** អនុប្រធានទីស្នាក់ការគយនិងរដ្ឋាករកំពង់ផែក្រុងព្រះសីហនុ សមាជិក
- លោកស្រី **សឹង សុធាណ្ណី** ជំនួយការការិយាល័យគ្រប់គ្រងហានិភ័យនិងសវនកម្ម សមាជិក

ខ- តំណាងផ្នែកឯកជន ៖

- តំណាងសភាពាណិជ្ជកម្មកម្ពុជា សហប្រធាន
- តំណាងសមាគមរោងចក្រកាត់ដេរកម្ពុជា អនុប្រធានអចិន្ត្រៃយ៍
- តំណាងសមាគមដឹកជញ្ជូនកម្ពុជា សមាជិក
- តំណាងក្រុមហ៊ុន Makalot Garments (Cambodia) Co., Ltd. សមាជិក
- តំណាងក្រុមហ៊ុន June Textiles Co., Ltd. សមាជិក
- តំណាងក្រុមហ៊ុន M & V International Manufacturing Ltd. សមាជិក
- តំណាងក្រុមហ៊ុន Generation International Co., Ltd. សមាជិក
- តំណាងក្រុមហ៊ុន Suntex PTE Ltd. សមាជិក
- តំណាងក្រុមហ៊ុន Phnom Penh SEZ Co., Ltd. សមាជិក

**ប្រការ ៤.-**

ក្រុមការងារគយ-ឧស្សាហកម្មបម្រើការនាំចេញវិស័យមិនមែនកាត់ដេរ មានសមាសភាពដូចខាងក្រោម ៖

ក- តំណាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ៖

- ប្រធាននាយកដ្ឋានកិច្ចការច្បាប់ សវនកម្ម និងទំនាក់ទំនងសាធារណៈ សហប្រធាន
- លោក **ម៉ុរ ម៉ុនណារ៉ា** ប្រធានការិយាល័យគយនិងរដ្ឋាករ អនុប្រធានអចិន្ត្រៃយ៍
- លោក **គីម ខួន** ប្រធានការិយាល័យគយនិងរដ្ឋាករ សមាជិក
- លោក **ផា អេងម៉េង** អនុប្រធានការិយាល័យត្រួតពិនិត្យ សមាជិក
- លោក **ប្រាក់ សុម៉េត** អនុប្រធានការិយាល័យគោលនយោបាយនិងគ្រប់គ្រងតំបន់រួចពន្ធ សមាជិក

- លោក **អ៊ីត សុផ្លារ៉ា** អនុប្រធានសាខាគយនិងរដ្ឋាករខេត្តព្រះសីហនុ សមាជិក
- លោក **សង់ សិទ្ធានិត្យ** ជំនួយការការិយាល័យត្រួតពិនិត្យ សមាជិក
- លោក **សាយ សេងឡាយ** ជំនួយការការិយាល័យគ្រប់គ្រងហានិភ័យនិងសវនកម្ម សមាជិក

ខ- តំណាងផ្នែកឯកជន ៖

- តំណាងសភាពាណិជ្ជកម្មកម្ពុជា សហប្រធាន
- តំណាងសមាគមសហគ្រាសតូច-មធ្យមកម្ពុជា អនុប្រធាន
- តំណាងសមាគមដឹកជញ្ជូនកម្ពុជា សមាជិក
- តំណាងក្រុមហ៊ុន KTC Cable Co., Ltd. សមាជិក
- តំណាងក្រុមហ៊ុន British American Tobacco Cambodia Co., Ltd. សមាជិក
- តំណាងក្រុមហ៊ុន Mong Rithy Group Co., Ltd. សមាជិក
- តំណាងក្រុមហ៊ុន Cambodia Brewery Limited. សមាជិក
- តំណាងក្រុមហ៊ុន Cambrew Ltd. សមាជិក
- តំណាងក្រុមហ៊ុន Crown Beverage Cans (Cambodia) Limited សមាជិក
- តំណាងក្រុមហ៊ុន C P Cambodia Co., Ltd. សមាជិក
- តំណាងក្រុមហ៊ុន Phnom Penh SEZ Co., Ltd. សមាជិក

**ប្រការ ៥.-**

ក្រុមការងារគយ-ធុរកិច្ចបម្រើទីផ្សារក្នុងស្រុកមានសមាសភាពដូចខាងក្រោម ៖

ក- តំណាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ៖

- ប្រធាននាយកដ្ឋានកិច្ចការច្បាប់ សវនកម្ម និងទំនាក់ទំនងសាធារណៈ សហប្រធាន
- ប្រធាននាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ អនុប្រធានអចិន្ត្រៃយ៍
- លោក **អ៊ុយ កុសល** អនុប្រធាននាយកដ្ឋានកិច្ចការច្បាប់សវនកម្ម និងទំនាក់ទំនងសាធារណៈ អនុប្រធាន
- លោក **ម៉ុរ ម៉ុនណារ៉ា** ប្រធានការិយាល័យគយនិងរដ្ឋាករ សមាជិក
- លោក **សង់ ស៊ីណាទិត្យ** ជំនួយការនាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ សមាជិក
- លោក **សុខ សុមិទ្ធា** ជំនួយការលេខាធិការដ្ឋាន សមាជិក
- លោក **រស់ ដារ៉ា** អនុប្រធានទទួលបន្ទុករួមការិយាល័យគោលនយោបាយគយ សមាជិក
- លោក **ដួង បូលីន** ជំនួយការលេខាធិការដ្ឋាន សមាជិក
- លោក **ម៉ិន អូន** ជំនួយការលេខាធិការដ្ឋាន សមាជិក

ខ- តំណាងផ្នែកឯកជន ៖

- តំណាងក្រុមហ៊ុន L.Y.P GROUP CO., LTD. សហប្រធាន
- តំណាងក្រុមហ៊ុន Unilever (Cambodia) Limited អនុប្រធាន
- តំណាងក្រុមហ៊ុន Good Will Trading Co., Ltd. សមាជិក

- តំណាងក្រុមហ៊ុន Good Hill Enterprise (Cambodia) Ltd. សមាជិក
- តំណាងក្រុមហ៊ុន Anco Brothers Co., Ltd. សមាជិក
- តំណាងក្រុមហ៊ុន Sok Kong Import Export Co., Ltd. សមាជិក
- តំណាងក្រុមហ៊ុន CHEVRON (Cambodia) Limited សមាជិក
- តំណាងក្រុមហ៊ុន Men Sarun Flour Factory Ltd. សមាជិក

**ប្រការ ៦.-**

យន្តការភាពជាដៃគូគយ-ផ្នែកឯកជន ដូចមានចែងក្នុងប្រការខាងលើមានតួនាទីដូចខាងក្រោម ៖

- សហការស្វែងយល់ទៅវិញទៅមក រវាងរដ្ឋបាលគយ និងផ្នែកឯកជន នូវរាល់សំណូមពរចាំបាច់នានា ដែលភាគីទាំងពីរចង់បាន ក្នុងគោលបំណងលើកស្ទួយសីលធម៌សារពើពន្ធ និងការសម្រួលពាណិជ្ជកម្មឲ្យបានជាអតិបរមា ជាពិសេសតម្រូវការនៃការយល់ដឹងពីបទប្បញ្ញត្តិជាធរមាន ការជម្រុញកម្រិតអនុលោមភាពច្បាប់ និងការធ្វើសាមញ្ញកម្មនីតិវិធីគយ ឈានទៅកាត់បន្ថយការចំណាយ និងការយឺតយ៉ាវនានាក្នុងការបំពេញបែបបទគយ
- សម្របសម្រួលឲ្យមានកិច្ចសហការយោគយល់គ្នាទៅវិញទៅមកល្អ តាមបទប្បញ្ញត្តិជាធរមាន រវាងរដ្ឋបាលគយ និងផ្នែកឯកជនពាក់ព័ន្ធ និងចូលរួមដោះស្រាយនូវរាល់បាតុភាពអសកម្ម និងភាពមិនយល់គ្នានានា ដើម្បីអនុវត្តគោលនយោបាយនៃកិច្ចសម្រួលពាណិជ្ជកម្មរបស់រាជរដ្ឋាភិបាលឲ្យមានប្រសិទ្ធភាព
- សម្របសម្រួលឲ្យមានការចូលរួមរបស់ផ្នែកឯកជនពាក់ព័ន្ធ ក្នុងដំណើរការកសាង និងកែសម្រួលបទប្បញ្ញត្តិនានា ជាពិសេសតារាងតម្លៃចម្លងការនៃទំនិញ ឲ្យមានអនុលោមភាពទៅតាមបញ្ញត្តិប្រកាសលេខ ៣៨៧ សហវ.ប្រក ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការកំណត់តម្លៃគិតពន្ធគយលើទំនិញនាំចូល ។

**ប្រការ ៧.-**

យន្តការភាពជាដៃគូគយ-ផ្នែកឯកជន ដូចមានចែងខាងលើមានសិទ្ធិ និងភារកិច្ចដូចខាងក្រោម ៖

- រៀបចំឲ្យមានកិច្ចប្រជុំ រៀងរាល់ដំណាច់ត្រីមាសនីមួយៗ ដើម្បីរួមគ្នាសម្របសម្រួលដោះស្រាយរាល់បញ្ហាមិនប្រក្រតីនានា ដែលត្រូវបានលើកឡើងដោយភាគីពាក់ព័ន្ធនៃបញ្ហានេះ ។ ក្នុងករណីយល់ថាចាំបាច់ ឬបន្ទាន់មិនអាចរង់ចាំបាន ប្រធានយន្តការភាពជាដៃគូគយ-ផ្នែកឯកជនអាចកោះប្រជុំវិសាមញ្ញនៅពេលណាមួយក៏បាន ។ យន្តការនេះមានសិទ្ធិអញ្ជើញតំណាងស្ថាប័នមានសមត្ថកិច្ច និងតំណាងផ្នែកឯកជនពាក់ព័ន្ធ ដើម្បីចូលរួមបំភ្លឺក្នុងកិច្ចប្រជុំនេះ
- ភាគីពាក់ព័ន្ធ ដូចមានចែងក្នុងបញ្ញត្តិប្រការ ៣ ប្រការ ៤ និងប្រការ ៥ នៃប្រកាសនេះ ដែលពុំមានបញ្ជាក់នាមជារូបវន្តបុគ្គលនោះ អាចចាត់តាំងតំណាងផ្លូវការរបស់ខ្លួនឲ្យមកចូលរួមប្រជុំ ដែលអាចផ្លាស់ប្តូរបានពីពេលមួយទៅពេលមួយ
- ផ្អែកតាមលទ្ធផលនៃកិច្ចពិភាក្សាសម្របសម្រួល និងក្នុងករណីតម្រូវឲ្យមានការសម្រេចដោយឡែកពីស្ថាប័នមានសមត្ថកិច្ចលើការកែសម្រួល បំពេញបន្ថែម ឬនិង ចេញសេចក្តីសម្រេច

ណាមួយបន្ថែមទៀតនោះ យន្តការនេះត្រូវចាត់ចែងរៀបចំឯកសារពាក់ព័ន្ធ ដាក់ជូនស្ថាប័នមានសមត្ថកិច្ចដើម្បីពិនិត្យ និងសម្រេច

- ត្រូវធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃរាល់កិច្ចប្រជុំ និងស្តីពីសកម្មភាពការងាររបស់ខ្លួនឲ្យបានទៀងទាត់ ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ប្រការ ៨.-**

មន្ត្រីរាជការគយនិងរដ្ឋាករដូចមានចែងក្នុងប្រការនានាខាងលើនៃប្រកាសនេះ ត្រូវបំពេញការកិច្ចតាមបញ្ញត្តិនៃប្រកាសនេះបន្ថែមលើមុខងារបច្ចុប្បន្ន ។

តាមសំណើរបស់ផ្នែកឯកជនពាក់ព័ន្ធ និងក្នុងករណីចាំបាច់ ប្រធានយន្តការភាពជាដៃគូគយ-ផ្នែកឯកជនអាចកែសម្រួល ឬបំពេញបន្ថែមសមាសភាពនៃក្រុមការងារជំនាញនីមួយៗនៃយន្តការនេះ ។

ការកែសម្រួល ឬបំពេញបន្ថែមសមាសភាពដឹកនាំយន្តការភាពជាដៃគូគយ-ផ្នែកឯកជន ដូចចែងក្នុងប្រការ ១ ខាងលើ ត្រូវកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ប្រការ ៩.-**

បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ១០.-**

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជា អគ្គលេខាធិការ អគ្គនាយក នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពនានានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងបុគ្គលពាក់ព័ន្ធទាំងអស់ ត្រូវអនុវត្តតាមប្រកាសនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន ៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- គណៈកម្មាធិការដឹកនាំការងារដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- គ្រប់សាលាខេត្ត-ក្រុងដែលពាក់ព័ន្ធ
- សភាពាណិជ្ជកម្មកម្ពុជា

"ដើម្បីជូនជ្រាប"
- ដូចប្រការ ១០ "ដើម្បីអនុវត្ត"
- ឯកសារ - កាលប្បវត្តិ